Australian Embassy
Cambodia

CDRI
Cambodia Development Resource Institute

## សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៥ ស្ដីពី៖
## "យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយ
## គុណភាពខ្ពស់ និងនិរន្តរភាព"

*ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥*

## សេចក្តីប្រកាសព័ត៌មានរួម
## ថ្នាក់ដឹកនាំកំពូលពិភាក្សាលើចំណុចអាទិភាពសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា
## នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា

ថ្ងៃនេះ អូស្ត្រាលី និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានរៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** សន្និសីទនេះមានការចូលរួមពីសំណាក់មន្ត្រីរាជការ ស្ថាប័នស្រាវជ្រាវ ដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញសេដ្ឋកិច្ចប្រមាណជាង ៥០០នាក់ ដើម្បីពិភាក្សា អំពីអាទិភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។

គណៈប្រតិភូថ្នាក់កំពូល រួមមាន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយរដ្ឋមន្ត្រី បីរូបទៀត រួមទាំង លោកជំទាវ ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI និងឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជានេះត្រូវបានប្រារព្ធឡើង នៅសណ្ឋាគារ សុខាភ្នំពេញ។ អ្នកចូលរួមក្នុងសន្និសីទនេះ ពិភាក្សាអំពីបញ្ហាប្រឈមជារចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ ក្នុងការជំរុញកំណើន និង ការអភិវឌ្ឍរបស់កម្ពុជា។ សន្និសីទនេះក៏មានរួមបញ្ចូល នូវប្រធានបទពិភាក្សាសំខាន់ៗ ទាក់ទងនឹងរបៀបវារៈ កំណែទម្រង់ ដើម្បីធានា

បាននូវកំណើន ដែលមានគុណភាពខ្ពស់ និងរយៈពេលវែង អភិបាលកិច្ចល្អ ការពង្រឹងស្ថាប័ន ការចូលរួមពីវិស័យឯកជន និងការអនុវត្តគោលនយោបាយអោយមានប្រសិទ្ធភាព។

ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី ដេរិក យីប បានមានប្រសាសន៍ថា "អូស្ត្រាលីមានសេចក្តីរីករាយក្នុងការគាំទ្រកិច្ចពិភាក្សាសំខាន់ៗទាំងនេះដើម្បីកំណត់អាទិភាពអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងបរិយាបន្ននៅកម្ពុជា។ សន្និសិទចក្ខុវិស័យកម្ពុជា គឺជាវេទិកាដ៏សំខាន់មួយ ដែលប្រមូលផ្តុំអ្នកជំនាញ និងអ្នកមានតួនាទីធ្វើការសម្រេចចិត្តលើគ្រប់វិស័យ ដើម្បីពិភាក្សាគ្នាលើយុទ្ធសាស្ត្រ និងមធ្យោបាយសមស្របសម្រាប់ការគាំទ្រកំណើនប្រកបដោយភាពរឹងមាំ និងភាពធន់នៅកម្ពុជា"។

លោកស្រីបណ្ឌិត អេង នេត្រា នាយិកាប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានមានប្រសាសន៍ថា "កម្ពុជាកំពុងឈានដល់ដំណាក់កាលសំខាន់មួយ ខណៈដែលកម្ពុជាកំពុងឆ្លងកាត់ស្ថានភាពមួយដែលមិនទាន់មានភាពច្បាស់លាស់។ វិទ្យាស្ថាន CDRI ប្តេជ្ញាក្នុងការបង្កើតចំណេះដឹងអភិវឌ្ឍន៍ ដែលនាំមកនូវឥទ្ធិពល និងផលជះជាវិជ្ជមានដែលរួមចំណែកដល់វិបុលភាពយូរអង្វែងរបស់កម្ពុជា តាមរយៈការស្រាវជ្រាវគោលនយោបាយ ការអភិវឌ្ឍសមត្ថភាព និងវេទិកាកិច្ចពិភាក្សារវាងវិស័យផ្សេងៗ ប្រកបដោយអត្ថន័យនិងខ្លឹមសារ ដូចជា សន្និសីទចក្ខុវិស័យកម្ពុជាជាដើម"។

សន្និសីទប្រចាំឆ្នាំនេះ គឺជាព្រឹត្តិការណ៍ពិភាក្សាគោលនយោបាយដ៏មានសារៈសំខាន់មួយ នៅក្នុងប្រទេសកម្ពុជា។ សន្និសីទនេះ គឺជាវេទិកាដ៏សំខាន់មួយ សម្រាប់ថ្នាក់ដឹកនាំក្នុងការពិភាក្សា ផ្លាស់ប្តូរយោបល់អំពីបញ្ហាសំខាន់ៗក្នុងប្រទេស ក៏ដូចជាកំណត់ទិសដៅគោលនយោបាយអភិវឌ្ឍន៍ ។

វិទ្យាស្ថាន CDRI បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ធំរបស់អូស្ត្រាលី ដែលមានឈ្មោះថា កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ដើម្បីរៀបចំសន្និសីទនេះឡើង។ ការសហការនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់អូស្ត្រាលី និងវិទ្យាស្ថាន CDRI ក្នុងការប្រមូលផ្តុំថ្នាក់ដឹកនាំសំខាន់ៗពីកម្ពុជា អាស៊ី និងតំបន់ដទៃទៀត ដើម្បីជំរុញកិច្ចសន្ទនាគោលនយោបាយមួយ ដែលគាំទ្រដល់កំណើនប្រកបដោយភាពធន់ បរិយាបន្ន និងនិរន្តរភាព។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**


ស្ថានទូតអូស្ត្រាលីៈ Media.Cambodia@dfat.gov.au

វិទ្យាស្ថាន CDRIៈ Chanvoleak.ros@cdri.org.kh